ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារជំនួយស្មារតី

# ស្តីពី

# រដ្ឋបាល និង រដ្ឋសហព័ន្ធ

បណ្ណាល័យច្បាប់-Law Library

lawlibrarysite.wordpress.com

# រដ្ឋទោល និង រដ្ឋសហព័ន្ធ

## ១) រដ្ឋទោល

**រដ្ឋទោល** គឺជារដ្ឋណាដែលនៅក្នុងរដ្ឋនោះមានការរៀបចំគ្រប់គ្រងនយោបាយ និងគតិយុត្តិតែមួយគត់នៅលើទឹកដី និងប្រជាជនរបស់ខ្លួនដោយអធិបតេយ្យ និងឯករាជ្យ។ មានន័យថាជារដ្ឋឯករាជ្យមួយដែលមិនស្ថិតក្រោមអាណានិគម រឺ ក្រោមចំនុះរបស់រដ្ឋដទៃណាមួយឡើយ។

ការគ្រប់គ្រងរដ្ឋគឺ មានការបែងចែកជាខេត្ត-ក្រុង-ស្រុក គឺធ្វើឡើងដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋបាលតែប៉ុណ្ណោះ។

នៅក្នុងរដ្ឋទោលគ្មានរដ្ឋនៅក្នុងរដ្ឋទេ គឺមានន័យថា រដ្ឋទោលជារដ្ឋគ្មានចំណុះរដ្ឋណាមួយឡើយ ហើយក៏គ្មានរដ្ឋណាមួយស្ថិតនៅក្នុងចំណុះរបស់ខ្លួនដែរ។ ឧ: ព្រះរាជាណាចក្រកម្ពុជា, ប្រទេសបារាំង, ប្រទេសអ៊ីតាលី, ប្រទេសថៃ។ល។

តាមនិយមន័យ រដ្ឋទោលគឺជាមជ្ឈការនយោបាយ ផ្ទុយទៅវិញក្នុងវិស័យរដ្ឋបាលការគ្រប់គ្រងអាចមានរបៀបជាមជ្ឈការ ឬវិមជ្ឈការ។

### ក) រដ្ឋទោលមជ្ឈការ

អ្វីទៅជាប្រព័ន្ធមជ្ឈការ?

ប្រព័ន្ធមជ្ឈការ គឺជាការគ្រប់គ្រងរដ្ឋបាលមួយប្រភេទដែលអំណាចកណ្តាលធ្វើការដឹកនាំរដ្ឋបាលរបស់រដ្ឋដោយផ្ទាល់ពីរដ្ឋបាលកណ្តាលរហូតដល់រដ្ឋបាលមូលដ្ឋាន ហើយរដ្ឋបាលដែនដីទាំងនេះគឺគ្រាន់តែជាប្រអប់សំបុត្រប៉ុណ្ណោះ។

ឬម្យ៉ាងទៀត ប្រព័ន្ធមជ្ឈការ គឺជាប្រព័ន្ធមួយដែលការងារទាំងអស់ ត្រូវបានកាន់កាប់ដោយរដ្ឋបាលថ្នាក់លើ (រដ្ឋាភិបាល) ហើយការងារអនុវត្តទាំងនេះ ត្រូវបានដាក់អោយ រដ្ឋបាលថ្នាក់ក្រោមអនុវត្តដែលថ្នាក់ក្រោមនេះ មាននាទីត្រឹមតែជាអ្នកដឹកនាំសមត្ថកិច្ចក្នុងការងារអនុវត្ត (ស្ពាន)ប៉ុណ្ណោះ។

មួយវិញទៀត ប្រព័ន្ធមជ្ឈការគឺជាប្រព័ន្ធដឹកនាំមួយដែលគ្មានការបោះឆ្នោតជ្រើសតាំងអំណាចកណ្ដាល ហើយអំណាចកណ្ដាលនេះចាត់តាំងថ្នាក់ក្រោមអោយធ្វើការជំនួស។ ថ្នាក់ក្រោមធ្វើអ្វីៗត្រូវសុំការអនុញ្ញាតពីអំណាចកណ្ដាលជាមុនសិន។

ដូច្នេះរដ្ឋទោលមជ្ឈការគឺជារបបគ្រប់គ្រងមួយ ដែលប្រមូលផ្ដុំអំណាចទៅថ្នាក់លើទាំងអស់ ថ្នាក់ក្រោមចាំតែទទួលបញ្ជា និងអនុវត្តទាំងស្រុងតែប៉ុណ្ណោះ។ អំណាចប្រមូលផ្ដុំនៅថ្នាក់លើនេះហៅថា "**អំណាចកណ្ដា-ល**"។

ក្នុងការជាក់ស្ដែងគេពុំអាចធ្វើបានទាំងអស់ ដោយស្រេចតែថ្នាក់លើ បញ្ជាមកយ៉ាងល្អិតល្អន់ក្នុងគ្រប់វិស័យ និងគ្រប់ករណីបាននោះទេ។ គេត្រូវបែងចែកអំណាចកណ្ដាលខ្លះប្រគល់អោយទៅភ្នាក់ងារតាមមណ្ឌលរដ្ឋបាលដែលនៅក្នុងប្រទេស។ ការបែងចែក (ការរំលែក) អំណាចកណ្ដាលនេះហៅថា មជ្ឈការរំលែកអំណាច ឬ វិសហមជ្ឈការ។

**ខ) <u>រដ្ឋទោលវិមជ្ឈការ</u>**

តើប្រព័ន្ធវិមជ្ឈការជាអ្វី?

ប្រព័ន្ធវិមជ្ឈការ គឺជាប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមួយ ដែលអាជ្ញាធររដ្ឋបាលកណ្ដាលទទួលស្គាល់នូវសិទ្ធិអំណាចក្នុងការសម្រេចរបស់អាជ្ញាធររដ្ឋបាលមូលដ្ឋាន ដោយមានចែងក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់នានា។ រីក៏ជាទម្រង់នៃការរៀបចំរបស់អំណាចនីតិប្រតិបត្តិរបស់រដ្ឋ ដោយធ្វើការទទួលស្គាល់សមូហភាពដែនដីជានីតិបុគ្គលសាធារណៈផ្សេង មានអំណាចក្នុងការសម្រេចកិច្ចការអ្វីៗដែលជាផលប្រយោជន៍រួមរបស់រាស្ត្រប្រជានៅក្នុងសមូហភាពនោះបាន។

ដូច្នេះ រដ្ឋទោលវិមជ្ឈការ គឺជារបបគ្រប់គ្រងរដ្ឋបាលមួយ ដែលមិនប្រមូលផ្ដុំអំណាចនៅតែថ្នាក់លើទាំងអស់ដោយអនុញ្ញាតអោយមានអំណាចផ្ទាល់នៅតាមទីតំបន់នៃដែនដី។

"**អំណាចផ្ទាល់**" គឺជាអំណាចសំរេចអ្វីមួយ ដោយខ្លួនឯងផ្ទាល់ ពុំចាំបាច់សុំគោលការណ៍ពីថ្នាក់លើជាមុនសិននោះទេ។

បើមានច្បាប់អនុញ្ញាតអោយខេត្ត,ក្រុង,ឃុំ មានអំណាចផ្ទាល់នេះ គឺគេនៅក្នុងរបបរដ្ឋទោលវិមជ្ឈការហើយ។

ឧៈ ប្រទេសបារាំង, ប្រទេសអ៊ីតាលី (ចែងក្នុងរដ្ឋធម្មនុញ្ញ)

- លក្ខខណ្ឌនៃវិមជ្ឈការៈ

-មានថវិកាដោយឡែក

-រដ្ឋអំណាចខេត្ត,ក្រុង កើតឡើងពីការបោះឆ្នោតរបស់ប្រជាពលរដ្ឋ។

**✵ រដ្ឋនោលវិសហមជ្ឈការ**

វិសហមជ្ឈការ គឺជាបច្ចេកទេសគ្រប់គ្រងរដ្ឋបាលមួយ ដែលអាជ្ញាធររដ្ឋបាលកណ្តាលបានរំលែកកិច្ចការមួយចំនួនទៅអោយអាជ្ញាធររដ្ឋបាលមូលដ្ឋានធ្វើការសំរេចដោយខ្លួនឯងផ្ទាល់ តាមការកំណត់ហើយសម្រេចតាងនាមអាជ្ញាធររដ្ឋបាលកណ្តាល។

ដូច្នេះអាជ្ញាធរមូលដ្ឋាន ធ្វើការសម្រេចកិច្ចការចាំបាច់ និងបន្ទាន់ខ្លះៗនៅនឹងកន្លែង(មូលដ្ឋាន) ដោយមិនចាំបាច់សុំការអនុញ្ញាត ក្នុងការសម្រេចពីអាជ្ញាធររដ្ឋបាលកណ្តាលដូចមុនឡើយ។ ព្រោះអាជ្ញាធរមូលដ្ឋាននៅពេលនេះ ទទួលបានសិទ្ធិអំណាចក្នុងការសម្រេច តាមការកំណត់អោយក្នុងលក្ខខណ្ឌដែលចែងច្បាស់លាស់ទៅហើយ។ ក្នុងការគ្រប់គ្រងរដ្ឋបាលតាមបច្ចេកទេសនេះ គឺជាការគ្រប់គ្រងតាមឋានានុក្រមរដ្ឋបាលដែលអំណាចកណ្តាលបានផ្តល់ដល់រដ្ឋបាលថ្នាក់ក្រោមសម្រេចតាមលំដាប់ថ្នាក់រៀងៗខ្លួន។

## ២) **រដ្ឋសហព័ន្ធ**

ជាទូទៅរដ្ឋសហព័ន្ធ នៅក្នុងនីតិអន្តរជាតិសាធារណៈ គឺជារដ្ឋមួយ ដែលកើតឡើងដោយមានរដ្ឋអធិបតេយ្យជាច្រើន។ យោងតាមនីតិអន្តរជាតិរដ្ឋសហព័ន្ធគឺជានីតិបុគ្គលអន្តរជាតិ។ រដ្ឋធម្មនុញ្ញសហព័ន្ធធ្វើការបែងចែកសមត្ថកិច្ចអោយរវាងរដ្ឋសហព័ន្ធ និង រដ្ឋសមាជិក ដែលជាទូទៅច្រើនតែប្រគល់អំណាចផ្តាច់មុខខាងកិច្ចការបរទេសអោយទៅរដ្ឋសហព័ន្ធ ប៉ុន្តែរដ្ឋជាសមាជិកនៃរដ្ឋសហព័ន្ធមានការធានាក្នុងការចូលរួមនៅក្នុងការសំរេចផ្សេងៗរបស់រដ្ឋសហព័ន្ធ។ គេអាចរាប់បញ្ចូលជារដ្ឋសហព័ន្ធដូចជា សហរដ្ឋអាមេរិក ស្វីស ឥណ្ឌាជាដើម។

### ក) **ធម្មនុញ្ញសហព័ន្ធ**

រដ្ឋធម្មនុញ្ញនេះ កំណត់សមត្ថកិច្ចរបស់សហព័ន្ធ និងរបស់រដ្ឋក្នុងសហព័ន្ធ។ រដ្ឋនៅក្នុងរដ្ឋសហព័ន្ធនីមួយៗមានរដ្ឋធម្មនុញ្ញ និងច្បាប់របស់ខ្លួនរៀងៗខ្លួន។ ប៉ុន្តែរដ្ឋនៅក្នុងរដ្ឋសហព័ន្ធគ្មានសមត្ថកិច្ចអន្តរជាតិទេ មានតែរដ្ឋសហព័ន្ធទេទើបមានសមត្ថកិច្ចអន្តរជាតិ និង នយោបាយទូត។

រដ្ឋក្នុងសហព័ន្ធគ្មានអធិបតេយ្យទេ។ មានការបែងចែកសមត្ថកិច្ចរវាងរដ្ឋសហព័ន្ធ និងរដ្ឋក្នុងសហព័ន្ធ កំណត់ដោយរដ្ឋធម្មនុញ្ញសហព័ន្ធ និងច្បាប់។

## ខ) ការបែងចែកអំណាចរវាងរដ្ឋសហព័ន្ធ និងរដ្ឋជាសមាជិក

### ខ.១. ការត្រួតគ្នានៃរដ្ឋ, រដ្ឋជាសមាជិក និងសហព័ន្ធ

➢ ប្រព័ន្ធគតិយុត្តសហព័ន្ធ នៅត្រួតពីលើប្រព័ន្ធគតិយុត្ត នៃរដ្ឋជាសមាជិក។ ដូច្នេះ រដ្ឋសហព័ន្ធដែលជារដ្ឋនៅពីលើមានអង្គការនយោបាយផ្សេងពីរដ្ឋជាសមាជិក។ នីតិ (ច្បាប់) សហព័ន្ធ អនុវត្តផ្ទាល់ក្នុងវិស័យនៃសមត្ថកិច្ច និងភ្លាមៗនៅក្នុងរដ្ឋជាសមាជិកដែលមានបុគ្គលភាពគតិយុត្ត។ រដ្ឋជាសមាជិកត្រូវគោរពរដ្ឋធម្មនុញ្ញសហព័ន្ធ និងគោលការណ៍សំខាន់ៗមួយចំនួនដូចជានីតិរដ្ឋ, ប្រជាធិបតេយ្យ។

➢រដ្ឋជាសមាជិកមិនមានអធិបតេយ្យទេ ទោះបីត្រូវបានគេហៅថា រដ្ឋ និងមានរដ្ឋធម្មនុញ្ញព្រមទាំងអំណាចស្វ័យភាពខាងផ្នែកនយោបាយ ឬច្បាប់។ ដោយឡែកចំពោះអធិបតេយ្យក្រៅប្រទេសវិញ គឺជាអំណាចរបស់រដ្ឋសហព័ន្ធ(ជាពិសេសនៅក្នុងវិស័យកងទ័ព, ការទូត, រូបិយវត្ថុ ឬទូរគមនាគមន៍)។ គេកត់សម្គាល់ឃើញថាមានការធ្វើប្រតិភូកម្មទៅអោយរដ្ឋជាសមាជិកមួយចំនួន។ ឧទាហរណ៍ រដ្ឋជាសមាជិក នៅអាល្លឺម៉ង់អាចធ្វើសន្ធិសញ្ញា ប៉ុន្តែត្រូវមានការព្រមព្រៀងពីរដ្ឋាភិបាលសហព័ន្ធ និងក្នុងវិស័យសមត្ថកិច្ចរបស់ខ្លួន។ ឧទាហរណ៍ *Canton Snine* អាចធ្វើសន្ធិសញ្ញាជាមួយរដ្ឋជិតខាង។

### ខ.២. ស្វ័យភាពរបស់រដ្ឋជាសមាជិក

រដ្ឋជា សមាជិកមានសមត្ថកិច្ចផ្ទាល់ តាមការកំណត់របស់រដ្ឋធម្មនុញ្ញសហព័ន្ធ។ រដ្ឋនីមួយៗ មានរដ្ឋធម្មនុញ្ញមួយដែលកំណត់អំពីការរៀបចំអង្គការនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ(ទម្រង់នៃការរៀបចំអង្គការទាំងបី ភាគច្រើនយកតាមសហព័ន្ធ លើកលែងតែនៅ *Canton* ស្វីសដែល *Exécutif* ភាគច្រើនកើតចេញពីការបោះឆ្នោតដោយផ្ទាល់របស់ប្រជាជន ផ្ទុយពី *Exécutif* សហព័ន្ធ ដែលសភាជាអ្នកបោះឆ្នោត)។

➢ការបែងចែកសមត្ថកិច្ចៈ

ការបែងចែកសមត្ថកិច្ចរវាងរដ្ឋសហព័ន្ធ និងរដ្ឋសមាជិក គឺមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ រដ្ឋធម្មនុញ្ញអាចកំណត់អំពីបញ្ជីសមត្ថកិច្ចរបស់រដ្ឋជាសមាជិក ដោយទុកឲ្យរដ្ឋសហព័ន្ធដោយសេរីនៅក្នុងវិស័យផ្សេងទៀត។ ជាញឹកញាប់រដ្ឋធម្មនុញ្ញរៀបរាប់អំពីសមត្ថកិច្ចដាច់ដោយឡែករបស់រដ្ឋសហព័ន្ធ ដោយមានព្រំដែនសមត្ថកិច្ចឯទៀតដែលសន្មត់ថាប្រគល់ឲ្យរដ្ឋជាសមាជិក។ នៅសហរដ្ឋអាមេរិក អំណាចដែលមិនប្រគល់ឲ្យ

រដ្ឋសហព័ន្ធ ហើយក៏មិនហាមឃាត់ចំពោះរដ្ឋសមាជិក ត្រូវបានប្រគល់ឲ្យ រដ្ឋសមាជិក ឬប្រជាជន (វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០)។ នៅអាល្លឺម៉ង់ "សិទ្ធិ ក្នុងការបញ្ញត្តិច្បាប់ជារបស់រដ្ឋសមាជិកគ្រប់ករណីដែលរដ្ឋធម្មនុញ្ញ មិនបានប្រគល់ឲ្យអំណាចនីតិបញ្ញត្តិសហព័ន្ធ"។

➢ សមត្ថកិច្ចផ្តាច់មុខរបស់សហព័ន្ធ៖

នយោបាយការបរទេស, ការពារជាតិ, រូបិយវត្ថុ, តុលាការសហព័ន្ធ, ពាណិជ្ជកម្ម, សញ្ជាតិ, សេរីភាពក្នុងការធ្វើដំណើរ។ល។

➢ សមត្ថកិច្ចត្រួតគ្នា៖ អាចអនុវត្តដោយសហព័ន្ធ និង រដ្ឋជាសមាជិក។

➢ សមត្ថកិច្ចបន្ថែម៖ អនុវត្តដោយរដ្ឋជាសមាជិក តាមការកំណត់របស់ច្បាប់សហព័ន្ធដែលកំណត់ពីគោល-ការណ៍ទូទៅ ហើយប្រគល់ឲ្យរដ្ឋជាសមាជិកអនុវត្ត។

**ខ.៣. <u>គោលការណ៍ចូលរួម</u>**

មានន័យថារដ្ឋជាសមាជិក ចូលរួមទៅក្នុងអំណាចរបស់រដ្ឋសហព័ន្ធ។ ការចូលរួមនេះមានច្រើនរូបភាព៖

➢ រដ្ឋជាសមាជិកចូលរួមក្នុងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។ នៅអាមេរិកវិសោធនកម្មត្រូវអនុម័តដោយសម្លេង ២/៣ ដោយ *Congrés* ក្នុងរយៈពេល ៧ឆ្នាំក្រោយមកត្រូវមានសម្លេងរបស់រដ្ឋ (សភារបស់រដ្ឋ) ចំនួន ៣/៤ឲ្យសច្ចាប័ន។ នៅអាល្លឺម៉ង់អាចកែបាន លុះត្រាមានការយល់ព្រមដោយសម្លេង២/៣នៃ *Bundestag* និង ២/៣ នៃ*Bundestrat*។

➢ ការចូលរួមក្នុងអំណាចនីតិបញ្ញត្តិ (ចូលរួមក្នុងការបញ្ចេញមតិនៅក្នុងសហព័ន្ធដោយឆ្លងតាមអ្នកតំណាង)។ សភារបស់រដ្ឋសហព័ន្ធមាន ២ គឺសភាតំណាងរាស្ត្រ និងសភាតំណាងរដ្ឋ។ ការជ្រើសតាំងសមាជិកសភាសហព័ន្ធជាទូទៅធ្វើឡើងដោយការបោះឆ្នោតជាសកល (លើកលែងអាល្លឺម៉ង់)។

➢ អំណាចនីតិបញ្ញត្តិរបស់សភាសហព័ន្ធ ប្រែប្រួលទៅតាមទម្រង់រដ្ឋនៅសហរដ្ឋអាមេរិក។ ក្រៅពីការចូលចូលរួមដោយស្មើភាពក្នុងការធ្វើច្បាប់ជាមួយសភាតំណាងរាស្ត្រ ព្រឹទ្ធសភាឲ្យការយល់ព្រមលើការតែងតាំងមន្ត្រីជាន់ខ្ពស់ដែលធ្វើឡើងដោយប្រធានាធិបតី។ នៅអាល្លឺម៉ង់ ច្បាប់សហព័ន្ធមួយចំនួនត្រូវយល់ព្រមដោយព្រឹទ្ធសភាដែលមានសិទ្ធិជំទាស់ (ជាពិសេសច្បាប់ដែលទាក់ទងនឹងទំនាក់ទំនងរវាងសហព័ន្ធ និងរដ្ឋសមាជិក)។

➢ការតែងតាំងអំណាចនីតិប្រតិបត្តិសហព័ន្ធ

នៅអាល្លឺម៉ង់ សភាពិសេសមួយដែលមានការចូលរួមពីសមាជិកសភាទាំងពីរចូលរួមតែក្នុងការបោះឆ្នោតប្រធានាធិបតីសហព័ន្ធ ចំណែកអធិការបតីដែលជាអ្នកកាន់អំណាចពិតប្រាកដ ត្រូវបានតែងតាំងដោយ *Bundestag*។ ដោយឡែកនៅសហរដ្ឋអាមេរិក ប្រធានាធិបតីត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល នៅក្នុងក្របខណ្ឌរដ្ឋជាសមាជិក។ យើងកត់សម្គាល់ថា កម្រិតសហព័ន្ធរដ្ឋជាសមាជិក អាចចូលរួមទៅក្នុងនីតិប្រតិបត្តិសហព័ន្ធ ដោយរដ្ឋធម្មនុញ្ញកំណត់ *(Belgique)*ឬដោយ *Convention (Canada)*។

## ៣) សេចក្ដីសន្និដ្ឋាន

តាមការរៀបរាប់ពីរដ្ឋទោល និងរដ្ឋសហព័ន្ធជាហូរហែលពីខាងលើមកយើងឃើញថា ប្រភេទនៃរដ្ឋមានពីរប្រភេទគឺ រដ្ឋទោល និងរដ្ឋសហព័ន្ធ ហើយរដ្ឋទាំងពីរនេះពិតជាមានលក្ខណៈខុសៗគ្នាមួយចំនួន។រួមសេចក្ដីមកយើងឃើញថា រដ្ឋទោល និងរដ្ឋសហព័ន្ធមានលក្ខណៈល្អរៀងៗខ្លួន។ ហើយការគ្រប់គ្រងរបស់រដ្ឋទាំងពីរនេះគឺមានបែបបទរបៀបរបបផ្សេងៗគ្នា។ តែការគ្រប់គ្រងទាំងនោះគឺមានលក្ខណៈល្អផងនិងមានលក្ខណៈមិនល្អផង៕

# ឯកសារយោង

- នីតិរដ្ឋធម្មនុញ្ញ (សាស្រ្តាចារ្យ សុខ យ៉ាន)
- ទំនាក់ទំនងអន្តរជាតិ (បណ្ឌិត ខៀវ ថារិកា)
- នីតិរដ្ឋបាលទូទៅ (អនុបណ្ឌិត ហៀង សាង)